ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០៥៨.......សហវ....ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វង់ថវិកាបុរេប្រទានសម្រាប់ឆ្នាំ២០១៧ របស់នាយកដ្ឋានសុខភាពសិក្សា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញ-វត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា ៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង អប់រំ យុវជន និកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្រ ហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកា គណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៦២ អយក.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ ១ ៖**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ" , ជំពូក៦១ "សេវាកម្ម" នៅនាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មីនៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២ ៖**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានសុខភាពសិក្សា ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ... ឆ្នាំ ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន** **បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៙៚ ៙

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានសុខភាពសិក្សា

## តារាងឧបសម្ព័ន្ធផ្ទេរឲ្យបុរេប្រទាន

## ថវិកាកម្មវិធីឆ្នាំ២០១៧ របស់អង្គភាពថវិកានាយកដ្ឋានសុខភាពសិក្សា

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | ភាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន ផ្ទេរទៅឲ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ជុំបង្វិល ផ្ទេរទៅឲ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | | | សរុបរួម ៖ | 635,100,000 | 605,100,000 | 491,304,800 | 113,795,200 | 122,826,200 | 81.2% |
| 60 | | | ការទិញ | 157,000,000 | 132,000,000 | 33,704,800 | 98,295,200 | 8,426,200 | 25.5% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 59,000,000 | 59,000,000 | 9,000,000 | 50,000,000 | 2,250,000 | 15.3% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 54,000,000 | 54,000,000 | 4,000,000 | 50,000,000 | 1,000,000 | 7.4% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 3,000,000 | 3,000,000 | 3,000,000 | - | 750,000 | 100.0% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 29,700,000 | 29,700,000 | 4,863,500 | 24,936,500 | 1,215,875 | 16.4% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 29,700,000 | 29,700,000 | 4,863,500 | 24,836,500 | 1,215,875 | 16.4% |
| | 6003 | | ស្បៀងអាហារ និងផលិតផលកសិកម្ម | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | | 60031 | ស្បៀង | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | 6005 | | សម្ភារៈតូចតាច សម្ភារៈ និងសម្ភារៈបរិក្ខារ | 56,300,000 | 31,300,000 | 7,841,300 | 23,458,700 | 1,960,325 | 25.1% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 27,300,000 | 27,300,000 | 3,841,300 | 23,458,700 | 960,325 | 14.1% |
| | | 60052 | សង្ហារឹម | 25,000,000 | | | | | #DIV/0! |
| | | 60053 | សម្ភារៈប្រើប្រាស់ | 4,000,000 | 4,000,000 | 4,000,000 | - | 1,000,000 | 100.0% |
| | 6007 | | សម្ភារៈបរិក្ខារថែទាំសុខភាព | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 60072 | សម្ភារៈបរិក្ខារពេទ្យ | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| 61 | | | សេវាកម្ម | 478,100,000 | 473,100,000 | 457,600,000 | 15,500,000 | 114,400,000 | 96.7% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុង និងក្រៅប្រទេស | 31,600,000 | 31,600,000 | 25,280,000 | 6,320,000 | 6,320,000 | 80.0% |
| | 6:05 | | ការថែទាំនិងជួសជុល | 38,000,000 | 38,000,000 | 38,000,000 | - | 9,500,000 | 100.0% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 5,000,000 | 5,000,000 | 5,000,000 | - | 1,250,000 | 100.0% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 61058 | ការថែទាំនិងជួសជុលផ្សេងៗ | 3,000,000 | 3,000,000 | 3,000,000 | - | 750,000 | 100.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 12,500,000 | 12,500,000 | 10,220,000 | 2,280,000 | 2,555,000 | 81.8% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 7,600,000 | 7,600,000 | 5,320,000 | 2,280,000 | 1,330,000 | 70.0% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 4,900,000 | 4,900,000 | 4,900,000 | - | 1,225,000 | 100.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 377,000,000 | 377,000,000 | 370,100,000 | 6,900,000 | 92,525,000 | 98.2% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 50,700,000 | 50,700,000 | 50,700,000 | - | 12,675,000 | 100.0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 43,200,000 | 43,200,000 | 42,410,000 | 790,000 | 10,602,500 | 98.2% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 283,100,000 | 283,100,000 | 276,990,000 | 6,110,000 | 69,247,500 | 97.8% |

| ជំពូក | គណនី | អនុគណនី | កាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានផ្ទេរទៅឲ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ដុំបង្វិលផ្ទេរទៅឲ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ដុំ | ៦=៣/២ |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 14,000,000 | 14,000,000 | 14,000,000 | - | 3,500,000 | 100.0% |
| | | 61132 | សោហ៊ុយបេសកកម្ម | 14,000,000 | 14,000,000 | 14,000,000 | - | 3,500,000 | 100.0% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 5,000,000 | - | - | - | - | #DIV/0! |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 5,000,000 | - | - | - | - | #DIV/0! |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ០៧ ខែ ឧសភ ឆ្នាំ២០១៧
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ

បណ្ឌិត វង្ស ប៊ុនឥន្ទ្រាវុធ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧
ជ.អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមគ្រូតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា

គិន_កោសល្ល

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៧
ប្រធាននាយកដ្ឋានថវិកា
ក្រសួងអប់រំ យុវជន និងកីឡា

វេជ្ជ.ឆាយគីម សុវណ្ណារី

ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៧
ផ្ទេរទៅឲ្យករបុរេប្រទាន

លី_វិតនៈ

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន